**សកម្មភាព** ៖ **ល្បែងជួយខ្ញុំផាត់ពណ៌**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែក សាច់ដុំភ្នែក)។

បំណិនចលកធំ (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)។

**បុរេគណិត**

ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ)។

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។

បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(បុរេគណិត)** ប្រាប់បានពីរបៀបរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "កុមារគំរូ "

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ខ្មៅដៃពណ៌ និងសន្លឹកកិច្ចការ (ផ្កា ខ្មៅដៃ ឡាន ផ្សិត ស្រកានាគ ខេទី)

(លោកគ្រូ និងអ្នកគ្រូធ្វើសន្លឹកកិច្ចការដោយខ្លួនឯងក៏បាន។

សូមស្រង់ចេញរូបភាពពីក្នុងផ្នុកឯកសារ "ប្រភេទរូបភាពជាច្រើនទៀត "។)

**ការរៀបចំ** ៖ ចែកសន្លឹកកិច្ចការ និងខ្មៅដៃពណ៌

**សេក្តីណែនាំ៖**

1. ប្រាប់ក្មេងៗថា ថ្ងៃនេះអ្នកគ្រូនឹងលេង**ល្បែងជួយខ្ញុំផាត់ពណ៌**ជាមួយកូនៗទាំងអស់គ្នា។
2. លោកគ្រូ /អ្នកគ្រូសួរសំណួរទៅកាន់ក្មេងៗដូចជា៖
   - តើកូនៗស្គាល់ពណ៌របស់ឥន្ទធនូដែរឬទេ? - ចាស/បាទ ស្គាល់/មិនស្គាល់
   - តើឥន្ទធនូមានប៉ុន្មានពណ៌? មានពណ៌អ្វីខ្លះ?

     - មាន៧ពណ៌ដូចជា ពណ៌ក្រហម លឿង ខៀវ បៃតង ស្វាយ ទឹកក្រូច ស...

- តើកូនៗចូលចិត្តពណ៌អ្វីជាងគេ? - ចាស/បាទ មាន៧ពណ៌ដូចជា ពណ៌ក្រហម លឿង ខៀវ បៃតង ស្វាយ ទឹកក្រូច ស...

3. ប្រាប់ក្មេងៗពីច្បាប់ក្នុងការលេងល្បែងនេះឱ្យច្បាស់សិន៖
   - ☐ ក្មេងៗអាចលេងទាំងអស់គ្នាមិនចាំបាច់ចែកជាក្រុម។
   - ☐ ចែកក្រដាសរូបភាពទៅកាន់ក្មេងៗម្នាក់ ១សន្លឹក និងខ្មៅដៃពណ៌។
   - ☐ ជ្រើសក្មេងតែម្នាក់ ដើម្បីឡើងទៅខាងមុខផាត់ពណ៌លើរូបភាពតែម្តងដោយមិនឱ្យអ្នកណាឃើញឡើយ។
   - ☐ បន្ទាប់មកប្រាប់ទៅមិត្តរួមថ្នាក់ទាំងអស់ឱ្យផាត់ពណ៌តាមដំណាក់កាល តាមអ្វីដែលគាត់និយាយ។ ឧទាហរណ៍៖សូមមិត្តរួមថ្នាក់ផាត់ស្លឹកពណ៌បៃតង បន្ទាប់មកផាត់ផ្លែពណ៌លឿង..
   - ☐ ពេលផាត់រួចរាល់ហើយត្រូវឱ្យក្មេងៗទាំងអស់លើករូបភាពបង្ហាញរបស់ពួកគេ និងប្រៀបធៀបគ្នាថាផាត់ពណ៌ដូចគ្នាដែរឬទេ?
   - ☐ ប្រសិនបើដូចគ្នាហើយ ត្រូវទះដៃអបអរទាំងអស់គ្នា ជាការស្រេច។
   - ☐ ចាប់ផ្តើមហៅក្មេងណាម្នាក់ផ្សេងទៀតឡើងទៅខាងមុខម្តង និងលេងដូចគ្នាដែរតែត្រូវផ្លាស់ប្តូររូបភាព។
4. ប្រាប់ពួកគេឱ្យលេងដោយមានភាពរីករាយ និងត្រូវយល់ពីគ្នាទើបល្បែងលេងហ្នឹងសប្បាយ។

**ការប្រែប្រួល៖**

ល្បែងសកម្មភាពនេះអ្នកអាចលេងជាគូរៗក៏បានដែរ។

- ☐ ចែកក្រដាសរូបភាពឱ្យក្មេងៗម្នាក់ ២សន្លឹក និងខ្មៅដៃពណ៌
- ☐ បែងចែកក្មេងៗជាពីរក្រុម ក្រុមទី ១ និងទី ២
- ☐ បន្ទាប់មកឱ្យក្មេងក្រុមទី ១ស្វែងរកក្មេងក្រុមទី ២ដើម្បីឱ្យជួយផាត់ពណ៌តាមខ្លួន
- ☐ ក្មេងដែលជាគូរត្រូវនៅជិតគ្នា គ្រូនិយាយប្រាប់ឱ្យក្មេងក្រុមទី១ផាត់ពណ៌ដែលខ្លួនស្រឡាញ់មុន បន្ទាប់មកឱ្យក្មេងក្រុម ១ប្រាប់ក្រុមទី ២ឱ្យផាត់ពណ៌តាមរូបខ្លួនឱ្យដូចគ្នាតែម្តង។
- ☐ ផ្លាស់ប្តូរឱ្យក្មេងក្រុមទី ២ផាត់ពណ៌មុនម្តង និងប្រាប់ឱ្យក្មេងក្រុមទី ១ផាត់ពណ៌តាមតាមពណ៌ដែលខ្លួនបានផាត់រួចនោះជាការស្រេច។